ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១២ លេខ ១១ សប្តាហ៍ទី ២ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១២

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

p

ក

មាតិកា

I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

៣១.០១.២០១២-ព្រះរាជក្រឹត្យ នស/រកត/០១១២/០៥៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីតំរោង ចំនួន ០៨ រូប ៩៣៣

០២.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៥៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ ចំនួន ១៥ រូប ៩៣៤

០៨.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៥៨ ស្តីពី ការតែងតាំង សមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និង តែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាន នៃ គណៈស្ថាបត្យករកម្ពុជា ចំនួន ៣៤ រូប ៩៣៥

០៨.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៥៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ៣០ រូប ៩៣៧

០៨.០២.២០១២ -ព្រះរាជក្រឹត្យ នស/រកត/០២១២/០៦០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ និង សប្បុរសជន ចំនួន ០៩ រូប ៩៣៩

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១០-០២-២០១២-អនុក្រឹត្យលេខ ២៣ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៩៤០

១២.០២.២០១២ -អនុក្រឹត្យលេខ ២៤ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ជូនទីស្តីការគណៈរដ្ឋមន្ត្រី ៩៤២

០៣.០២.២០១២ -អនុក្រឹត្យលេខ ១៣១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៩៤៤

០៣.០២.២០១២ -អនុក្រឹត្យលេខ ១៣២ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ៩៤៥

០៣.០២.២០១២ -អនុក្រឹត្យលេខ ១៣៣ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩៤៦

០៦.០២.២០១២ -អនុក្រឹត្យលេខ ១៣៤ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៤៧

០៦.០២.២០១២ -អនុក្រឹត្យលេខ ១៣៥ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៤៨

០៦-០២-២០១២ -អនុក្រឹត្យលេខ ១៣៦ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិ នាយទាហាន ៥៤៩
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៣៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៥២
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៣៨ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ៥៥៤
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៣៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៥៥
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៤០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៥៦
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៤១ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៥៧
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៤២ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៥៩
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៤៣ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៦៧
០៦-០២-២០១២ -អនុក្រឹត្យលេខ ១៤៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៥៦៩
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៤៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧១
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៤៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៣
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៤៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៤
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៤៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៦
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៤៩ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ ៥៧៧
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៨
០៨-០២-២០១២ -អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៧៩
០៩-០២-២០១២ -អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៨១
០៩-០២-២០១២ -អនុក្រឹត្យលេខ ១៥៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៨២
១០-០២-២០១២ -អនុក្រឹត្យលេខ ១៥៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨៤
១០-០២-២០១២ -អនុក្រឹត្យលេខ ១៥៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៥
១០-០២-២០១២ -អនុក្រឹត្យលេខ ១៥៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៨៧
១០-០២-២០១២ -អនុក្រឹត្យលេខ ១៥៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៨៨
១០-០២-២០១២ -អនុក្រឹត្យលេខ ១៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៨៩
១០-០២-២០១២ -អនុក្រឹត្យលេខ ១៥៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៩១
១០-០២-២០១២ -អនុក្រឹត្យលេខ ១៦០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៩៤

២.សារាចរណែនាំ

០៣-០២-២០១២ -សារាចរណែនាំលេខ ០១ សរណន ស្តីពី ការអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា ៥៩៥

III. ការងារបណ្ដាក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០១-១១-២០១០-លិខិតបញ្ជាក់លេខ ៥៤៥១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខ្យូ & មាស អេសធីអេន** ១០០៣

០១-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៥៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី ស្ទានីម គ្រុប** ១០០៥

០២-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថៃហ្វូ វ៉ាប់ប៊ើរ (ខេមបូឌា)** ១០០៧

០២-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វុង អាន (ជីន ឌូ ចាយ) ជុង ចេង យូ ស៊ាង** ១០០៩

០២-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៦៥ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីលើការបង្កើតសាខាក្រុមហ៊ុន **ជីប ម៉ុង ខនត្រឹត (ស៊ីអិមស៊ី) ខូ អិលធីឌី** ១០១១

០២-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៦៧ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការបង្កើតសាខារបស់ក្រុមហ៊ុន **អេច អេស ស៊ី ខូ អិលធីឌី** ១០១២

០២-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៦៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាត់ ថង ផាតនើស៊ីប ខូ អិលធីឌី** ១០១៣

០២-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៦៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គ្រីន លែន & លីហ្វ ផេសធីសាយ** ១០១៥

០៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៧៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ៊ីតាយ៉ាត់ ប៊ុយមី (ខេមបូឌា)** ១០១៧

០៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៧៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយ យង (ខេមបូឌា) ត្រេឌីង** ១០១៩

០៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៨០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រូខំតូ ហ្វីដ ខបភើរេសិន** ១០២១

០៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៨២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អ.ធី.ឌី គ្រុប (ខេមបូឌា)** ១០២៣

០៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៩៥ ពណ.ចបព ស្តីពី ការទទួលចុះបញ្ជីនូវការបង្កើនដើមទុនចុះបញ្ជីពាណិជ្ជកម្ម និង តំកល់ទុកលក្ខន្តិកៈថ្មីរបស់ក្រុមហ៊ុន **តាម៉ារេដន្ទ ខេនឈ័រ (ខេមបូឌា) លីមីធីត** ១០២៥

០៣-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៩៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខាំម៉ា ឌើលដ៍** ១០២៧

០៧-១២-២០១០-លិខិតបញ្ជាក់លេខ ៥៤៩៩ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេស្តខ្សែត រីហ្សូត** ១០២៩

០៧-១២-២០១០-លិខិតបញ្ជាក់លេខ ៥៥០០ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌីអេសអេច គ្លូបិល សឺលូសិន** ១០៣១

p

ព្រះរាជក្រឹត្យ

នស/រកត/០១១២/០៥៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំនិងមន្ត្រីអនុវត្តតំរោង ចំនួន ០៨ រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចខិតខំយកអស់កម្លាំង កាយចិត្ត សាងសង់ផ្លូវជាតិលេខ ៧៦ ពីស្នួល (ខេត្តក្រចេះ) ដល់សែនមនោរម្យ (ខេត្តមណ្ឌលគិរី) ប្រវែង ១២៧ គ.ម រហូតបានចប់រួចរាល់ជាស្ថាពរ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោក **ភី សុភាត់** ២- លោក **ស្រេង ស្រស់**
៣- លោក **ម៉ៅ ធនារក្ស**

ខ- គ្រឿងឥស្សរិយយស **ព្រះមហាក្សត្រិយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- ឯកឧត្តម **ញ៉ុំ ច័ន្ទសុវណ្ណារី**

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- លោក **កង ភិរុទ្ធ** ២- លោក **សឿន ប៊ុនណឺ**
៣- លោក **យ៉ាត យ៉េត**

ឃ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

- លោក **ប៉ោ យុទ្ធថា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការសំបន្ទាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ចរល.០១២០១.០៥៩

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ: ... ច.ល
... ចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ២០១២
... ជ្ញាតិបាល

... សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៥៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ចំនួន ១៥ រូប មានគុណបំណាច់ចំពោះជាតិមាតុភូមិ និងស្នាដៃល្អប្រសើរ
ក្នុងការសាងសង់អគារមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ
និងអគារទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

នូវ

ក- គ្រឿងឥស្សរិយយស **ជាតូបការ** :

១- ឯកឧត្តម **ឆាន់ សាផាន** ២- ឯកឧត្តម **រ័ត្ន សារិន**
៣- ឯកឧត្តម **ប្រាក់ ហាម**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- លោក **ឆាយ ឫទ្ធិសែន**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **អ៊ឹម ចំរុង** ២- លោក **ជួរ វុឌ្ឍី**
៣- លោក **លឹម ប៊ូ**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **កើត សារ៉េត** ២- លោក **ញ៉ែន ស៊ី**
៣- លោក **កែវ កុសល** ៤- លោក **ឡៅ មិត្តសីហា**
៥- លោក **ហង្សសុត សំភារ**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- លោក **សេង ឡុត** ២- លោក **កែវ វុំហ្ស**
៣- លោក **ឡាយ ជំរើម**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧.១២០២.០៦០

ច.ល
ឆ្នាំ២០១២

p

ព្រះរាជក្រឹត្យ

នស/រកត/០២១២/ ០៥៥

ស្តីពី

ការកំណត់សមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា និងតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាន នៃគណៈស្ថាបត្យករកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាគណៈស្ថាបត្យករកម្ពុជា ដូចខាងក្រោម:

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**	នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា	ប្រធានកិត្តិយស
១- ឯកឧត្តម **អ៊ឹម ឈុនលឹម**	ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	ប្រធាន
២- ឯកឧត្តម **អ៊ឹម សិទ្ធី**	រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
៣- ឯកឧត្តម **ហ៊ឹម ឆែម**	រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	អនុប្រធាន
៤- ឯកឧត្តម **ត្រាំ អ៊ីវតឹក**	រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៥- ឯកឧត្តម **សំ មុនីត**	ប្រធានគណៈកម្មាធិការជាតិបេតិកភណ្ឌពិភពលោក	អនុប្រធាន
៦-ឧកញ៉ា **គិត ម៉េង**	ប្រធានសភាពាណិជ្ជកម្មកម្ពុជា	សមាជិក
៧-ឧកញ៉ា **ពុង ឃាវសែ**	ប្រធានសមាគមអ្នកសាងសង់កម្ពុជា	សមាជិក
៨- ឯកឧត្តម **ហ៊ុយ ណារ៉ា**	អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន	សមាជិកអចិន្ត្រៃយ៍
៩- ឯកឧត្តម **អ៊ិត ប្រាំង**	រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១០- ឯកឧត្តម **សួស គង់**	រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១១- ឯកឧត្តម **ឿង សុភ័ណ្ឌ**	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១២- ឯកឧត្តម **ប៉ាន់ សុរស័ក្តិ**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
១៣- ឯកឧត្តម **ឃិន តឹមសាន**	រដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS •
ព្រះបរមរាជវាំង

p

១៤- ឯកឧត្តម **អ៊ុន ធីរជាតិ**	ប្រធានក្រុមប្រឹក្សាភិបាលសមាគម គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា	សមាជិក
១៥- ឯកឧត្តម **អ៊ុំ ប៊ុនធឿន**	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់	សមាជិក
១៦- ឯកឧត្តម **ច័ន្ទ សំណាព**	អនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា	សមាជិក
១៧- ឯកឧត្តម **ម៉ម សុផាណា**	អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
១៨- ឯកឧត្តម **លី ឈូត្រែ**	សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	សមាជិក
១៩- ឯកឧត្តម **ឆៀវ ឈីធរិច**	សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ	សមាជិក
២០- ឯកឧត្តម **ឃុត សុចត្ថិ**	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ	សមាជិក
២១- ឯកឧត្តម **អ៊ឹម រឿយណី**	នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា	សមាជិក
២២- ឯកឧត្តម **អ៊ិច សេង**	សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យមេគង្គកម្ពុជា	សមាជិក
២៣- លោក **លឹម ធីរក្ស**	ប្រធាននាយកដ្ឋានក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
២៤- លោក **ចាន់ សុឃាង**	សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យន័រតុន	សមាជិក
២៥- លោក **ឡៀប សីហា**	សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យបៀលប្រាយ	សមាជិក។

មាត្រា ២.- ត្រូវបានតែងតាំងសមាសភាពអគ្គលេខាធិការដ្ឋាន នៃគណៈស្តាបត្យករកម្ពុជា ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម **ហ៊ុយ ណារ៉ា**	អគ្គលេខាធិការ	មានឋានៈស្មើរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
២- ឯកឧត្តម **ជី ស៊ីថា**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៣- ឯកឧត្តម **ឆាយ ឫទ្ធីសែន**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៤- ឯកឧត្តម **ញ៉ែន ស៊ី**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៥- ឯកឧត្តម **ចេងហុង សុជាតិខេមរ៉ា**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៦- ឯកឧត្តម **ម៉ែន សុផល**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៧- ឯកឧត្តម **ម៉េង ប៊ុណ្ណារិទ្ធ**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន
៨- ឯកឧត្តម **ឆៀវ និព្វសីហា**	អគ្គលេខាធិការរង	មានឋានៈស្មើអនុរដ្ឋលេខាធិការ	បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ៣.- សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤.- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២

ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

នរស.១២០២.០៦៣

លេខ: ៧៤ ច.ល

...ចែក

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០១២

...រដ្ឋាភិបាល

...យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១២/០៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

កងកំលាំងប្រដាប់អាវុធ និង សប្បុរសជន ចំនួន ៣០ រូប មានស្នាដៃល្អ ក្នុងការជួយកសាង អាគារស្នាក់នៅ និង សមិទ្ធផលនានាជាច្រើន នៅទីបញ្ជាការដ្ឋានអង្គរក្សប្រចាំទិសប្រាសាទព្រះវិហារ

នូវ

ក- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍:

១-ឧត្តមសេនីយ៍ទោ **ស៊ី ហ៊ីហ៊ុយ**
២-ឧត្តមសេនីយ៍ទោ **គង់ ម៉ិនលី**
៣-ឧត្តមសេនីយ៍ទោ **កើត ប៉ូលីន**
៤-ឧត្តមសេនីយ៍ទោ **គីម តិច**
៥-ឧត្តមសេនីយ៍ទោ **ម៉ិន រ៉ា**
៦-ឧត្តមសេនីយ៍ត្រី **ម៉ិន សុខា**
៧-ឧត្តមសេនីយ៍ត្រី **ហ៊ុយ ថេរ៉ា**
៨-ឧត្តមសេនីយ៍ត្រី **មុំ សម្ភស្ស**
៩-ឧត្តមសេនីយ៍ត្រី **គិត ទៀ**
១០-ឧត្តមសេនីយ៍ត្រី **ជុក គឹមសាន**
១១-ឧត្តមសេនីយ៍ត្រី **ស្រួន សុធី**
១២-ឧត្តមសេនីយ៍ត្រី **ញ៉ាន សុជាត្រា**
១៣-ឧត្តមសេនីយ៍ត្រី **អៀម សាម័យ**
១៤-ឯកឧត្តម **អ៊ុន ចាន់ដា**
១៥-លោក **ម្នាស់ លីម**
១៦-លោក **ឃឹម សារ៉ាន់**
១៧-លោក **ខឹម ចិត្រា**
១៨-លោក **មួង ដារ៉ា**
១៩-លោក **គ្រួច សម្បត្តិ**
២០-លោក **មាស ស៊ីថា**

ខ- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា:

១-ឧត្តមសេនីយ៍ត្រី **យ៉ន់ ម៉ៅ**
៥-លោក **តាំង ឈុនតាំង**

២-លោកជំទាវ	**ឆា ដារី**	៦-លោក	**សោម ជាតិ**
៣-លោក	**ហ៊ី សុខហេង**	៤-លោក	**តាំង សុខជា**
៧-លោក	**ផាត់ សាធុទ្ធ**	៨-លោក	**យ៉ាន់ ច័ន្ទផល**
៩-លោក	**ជា គឹមសេង**	១០-កញ្ញា	**ខន អរ៉ែណ្ណត**

រាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

១២០២.០៦៤

ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ... ខែកុម្ភៈ ឆ្នាំ២០១២

... ព្រះរាជាណាចក្រ ... គឺបាល

ព្រះរាជក្រឹត្យ

យើង

នស/រកត/០២១២/០៦០

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ព្រះសង្ឃ និងសប្បុរសជន ចំនួន ០៩ រូប មានស្នាដៃល្អ ក្នុងការចូលរួមកសាងព្រះវិហារ
និងសមិទ្ធផលនានា នៅវត្តប្រាសាទ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឧបាសិកា **គាត់ ឡឹង**
២- ឧបាសិកា **សុខ ជុំ**
៣- លោកជំទាវ **មុំ ម៉ានិត**
៤- ឧត្តមសេនីយ៍ត្រី **ម៉ិន ហៀង**
៥- ឧត្តមសេនីយ៍ត្រី **អែម សាម៉ុន**

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

- ឧត្តមសេនីយ៍ត្រី **គង់ ចន្ទដារ៉ា**

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- ព្រះតេជគុណ **លឹម សុភាព**
២- លោក **ង៉ៃ ធូនផ្កាមកេសន**
៣- លោកស្រី **ខៀវ លក្ខិណា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១២

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

៣លេ.១២០២.០៦៥

ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ ... ច.ល
ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១២
... អគ្គនាយករដ្ឋបាល
... សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- តាមសំណើ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តាមសំណើ របស់សាលាខេត្តកំពង់ស្ពឺ
- តាមសំណើ របស់សាលារាជធានីភ្នំពេញ

សម្រេច

មាត្រា ១ :-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវទីតាំង៖

-ពិសោធន៍កសិកម្មស្ថិតនៅផ្លូវលេខ៦អា សង្កាត់ព្រែកលៀប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានផ្ទៃដីទំហំ ១៨៧.០៧៤,៥៧ ម៉ែត្រក្រឡា ។

-ចំណតរថយន្ត ស្ថិតនៅភូមិពាណិជ្ជកម្ម សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដែលមានផ្ទៃដីទំហំ

p

៨ ២៦០ ម៉ែត្រក្រឡា។

-ស្រះចិញ្ចឹមត្រី ស្ថិតនៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានផ្ទៃដីទំហំ ១៥០.០០០ ម៉ែត្រក្រឡា។

មាត្រា ២ :-

ការលប់ទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាលាខេត្តកំពង់ស្ពឺ សាលារាជធានីភ្នំពេញ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣ :-

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ :-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អភិបាលរាជធានីភ្នំពេញ អភិបាលខេត្តកំពង់ស្ពឺ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល__

ក្រសួងព្រះបរមរាជវាំង

- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ជូនទីស្តីការគណៈរដ្ឋមន្ត្រី

រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស /រកត /១០៩០៨ /១០៥៥, ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រមលេខ០២ នស/៩៤, ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦,ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០១៩, ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ២០១២

បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក, ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក, ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋាន ហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និងអនុក្រឹត្យលេខ២០អនក្រ. បក, ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋ កិច្ចនិងហិរញ្ញវត្ថុ

បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឲ្យទៅជាអគ្គ នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បានឃើញអនុក្រឹត្យលេខ ២៨៧ អនក្រ.បក, ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ ២០១១ ស្តីពីការបែងចែកចំណាយ ឥណទានថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១២

តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

p

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតផ្ទេរឥណទានថវិកាចំនួន ៣០ ០០០លានរៀល (សាមសិបពាន់លានរៀល) ពីជំពូក០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក៦៥(ឧបត្ថម្ភ និងជំនួយសង្គម)ទៅលើសៀវភៅថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រីសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ។

មាត្រា២: ឥណទានថវិកាដូចមានក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦៥ សម្រាប់ឥណទានពិសេសនៅក្នុងខ្ទង់ចំណាយពិសេសរបស់រាជរដ្ឋាភិបាលដើម្បីចំណាយក្នុងកិច្ចការប្រាសាទព្រះវិហារ ។ ការបញ្ជាចំណាយនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់នាយករដ្ឋមន្ត្រី ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនីត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាបេឡាករនៃឥណទានពិសេសនេះ ។

មាត្រា៤: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១: តែងតាំងលោក **កែវ សុវត្ថិ** ជាទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានឋានៈស្មើអគ្គនាយករង ។

មាត្រា ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- ប្រកាសលេខ ៦៣១ មសក្រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១ របស់រដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ

សម្រេច

មាត្រា ១:ត្រូវបានតម្លើងឋានន្តរស័ក្តិលោក **លី ស៊ីណា** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ១១ ទៅឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ ១០ នៃក្របខណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅទីស្តីការគណៈរដ្ឋ មន្ត្រី។

មាត្រា ២:បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣:រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ: ១៣៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

សម្រេច

មាត្រា ១ : ប្រគល់ភារកិច្ចជូនលោក **ផារ៉ា មង្គល** អនុមន្ត្រីថ្នាក់លេខ ១២ ឱ្យបំពេញមុខងារជាអគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអភិវឌ្ឍន៍ជនបទ ជំនួសលោក ហៀង សុវណ្ណារ៉ា ដែលបានលុបឈ្មោះចេញពីក្របខ័ណ្ឌ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនជំនាញការវៀតណាម ចំនួន ០២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច អនុវត្តការដាំដុះកៅស៊ូទៅតាមផែនការ ដែលបានគ្រោងទុក និងធ្វើសហប្រតិបត្តិការល្អ ជាមួយសហព័ន្ធសហជីពឯករាជ្យកម្ពុជា ក្នុងការចងក្រងសហជីពនៅតាមសម្ព័ន្ធវៀតណាម ចំនួន០៧ ដែលស្ថិតនៅក្នុងខេត្តកំពង់ធំ និងខេត្តក្រចេះ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសហមេត្រី ថ្នាក់ និបនិន្ទ

- លោក TRAN VIET HUNG

ខ-មេដាយសហមេត្រី ថ្នាក់ សេនា

- លោក TRAN NGOC THUAN

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៥ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ជូនមន្ត្រីអង្គការ ចំនួន ០៣រូប ដែលមានស្នាដៃល្អ លើការងារគាំទ្រ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ការស្តារជីវភាព និងសង់ជម្រកស្នាក់នៅជូនជនពិការ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធបរិវេណមណ្ឌលជនពិការបន្ទាយប្រាប ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

១- លោក GABRIEL BYONG YOUNG JE ប្រធានក្រុម Jesuit Service Cambodia(JSC)

២- លោក GREG PRIYADI ប្រធានអង្គការ Jesuit Service Cambodia(JSC)

៣- លោក OH INDON ប្រធានមណ្ឌល និងតំណាងអង្គការ Jesuit Service Cambodia(JSC)

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ [illegible] ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរសក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ចុះថ្ងៃទី១៨ខែកក្កដាឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៦៥អនក្រ.បកចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានដំឡើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក នាយទាហាន នៃកងយោធពលខេមរភូមិន្ទដែលមានរាយនាមដូចខាងក្រោម ៖

១-វរសេនីយ៍ទោ	**ចៅ**	**តុលា**	អត្តលេខ ០១១៧៣៥	នាយទាហានការពារផ្ទាល់បញ្ជាការដ្ឋានអង្គរក្ស
២-វរសេនីយ៍ទោ	**ចៅ**	**មករា**	អត្តលេខ ០១៧៦២៤	នាយទាហានការពារផ្ទាល់បញ្ជាការដ្ឋានអង្គរក្ស
៣-វរសេនីយ៍ទោ	**រស់**	**សុភាព**	អត្តលេខ ០២១២១១	នាយទាហានការពារផ្ទាល់បញ្ជាការដ្ឋានអង្គរក្ស
៤-វរសេនីយ៍ទោ	**ជា**	**សាវ៉េត**	អត្តលេខ ២២០១៩១	នាយទាហានការពារផ្ទាល់បញ្ជាការដ្ឋានអង្គរក្ស

p

៥-វរសេនីយ៍ទោ	នុយ	សាអ៊ាន	អត្តលេខ ២៣២៩៣១	នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស
៦-វរសេនីយ៍ទោ	ញ៉ាច	ដារ៉ា	អត្តលេខ ១៣២១៥៣	នាយទាហានការពារផ្ទាល បញ្ជាការដ្ឋានអង្គរក្ស
៧-វរសេនីយ៍ទោ	ឈឿន	ឈិន	អត្តលេខ ២៣២២៦៨	នាយទាហានការពារផ្ទាល បញ្ជាការដ្ឋានអង្គរក្ស
៨-វរសេនីយ៍ទោ	ចក់	ស៊ីថុន	អត្តលេខ ០២១២៦៥	នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស
៩-វរសេនីយ៍ទោ	ស៊ឹម	សារ៉ាឌុន	អត្តលេខ ០៦៣៣១៥	នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស
១០-វរសេនីយ៍ទោ	មុំ	សាឡឿត	អត្តលេខ ១៦២៣៤០	នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស
១១-វរសេនីយ៍ទោ	ហៀង	ម៉ិនសេង	អត្តលេខ ០១១៧៦៦	នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស
១២-វរសេនីយ៍ទោ	ឡុញ	សំណាង	អត្តលេខ ១០៨៣៨៩	នាយទាហានការពារផ្ទាល់ បញ្ជាការដ្ឋានអង្គរក្ស
១៣-វរសេនីយ៍ទោ	ឡៀង	ចន្ថា	អត្តលេខ ០៣៩៣៣៩	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៤-វរសេនីយ៍ទោ	សុខ	ម៉េង	អត្តលេខ ០១៣៩៥៨	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៥-វរសេនីយ៍ទោ	ញួង	ផ្កា	អត្តលេខ ០១៣៧៩២	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៦-វរសេនីយ៍ទោ	ខួន	ចិន្ទ	អត្តលេខ ០០៨៣៣៣	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៧-វរសេនីយ៍ទោ	ទ្រួក	តាន	អត្តលេខ ០១១០០៨	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៨-វរសេនីយ៍ទោ	មាស	សម្បត្តិ	អត្តលេខ ០៣៩៣២០	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
១៩-វរសេនីយ៍ទោ	អេង	ធុនី	អត្តលេខ ០៨៨៥២០	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា
២០-វរសេនីយ៍ទោ	ឃិន	សុខ	អត្តលេខ ០១៩៧០៥	នាយទាហានការពារផ្ទាល់ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា

p

២១-វរសេនីយ៍ទោ **ព្រាប** **មុរិន្ទ** អត្តលេខ ០១១០០៧ នាយទាហានការពារផ្ទាល់អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា

២២-វរសេនីយ៍ទោ **ទ៉ា** **រិទ្ធី** អត្តលេខ ០០៣៣៦៥ នាយទាហានការពារផ្ទាល់អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា

២៣-វរសេនីយ៍ទោ **សួស** **សទ្ធា** អត្តលេខ ០២៨៨១៨ នាយ ការិយាល័យផែនការសិក្សាគំរោងនិងស្រាវជ្រាវ នាយកដ្ឋានផលិតសម្ភារៈយោធា អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

២៤-វរសេនីយ៍ទោ **ហ៊ិន** **សំណាង** អត្តលេខ ០០៨៦៦៣ ជំនួយការ ឯកឧត្តម **ម៉ែន ចាន់ណារ៉ា** អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

២៥-វរសេនីយ៍ទោ **ម៉ែន** **តិរម្យ** អត្តលេខ ១៩៨៦៧៨ ជំនួយការ ឯកឧត្តម **ម៉ែន ចាន់ណារ៉ា** អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

មាត្រា២៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងបណ្តាសាមីខ្លួនដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៣១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.–

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ២១រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តសិរីវង្សវិជុំ**(ហៅវត្តក្រាំងឫស្សី) ស្ថិតនៅក្នុងឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលមានរាយនាមដូចខាងក្រោម :

ក. មេដាយមាសស្ថាបនាជាតិចំនួន ១២ គ្រឿង ផ្តល់ជូន :

១-ឧបាសក **សួស សារ៉ុល** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៦.៧៥០ ដុល្លារ

២-លោក **ជឹប ម៉េង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៦.៧០០ ដុល្លារ

៣-ឧបាសក **យ៉ាន់ យ៉េម** សប្បុរសជននៅខេត្តកណ្តាល ថវិកាចំនួន ១៦.៥០០ ដុល្លារ

៤-ឧបាសក **ម៉ុន ជា** សប្បុរសជននៅខេត្តកំពង់ស្ពឺ ថវិកាចំនួន ១៥.៨៥០ ដុល្លារ

៥-ឧបាសក **ឈុប កុសល** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៥.៧៥០ ដុល្លារ

៦-ឧបាសក **អ៊ួច សុខអាន** សប្បុរសជននៅខេត្តកណ្តាល ថវិកាចំនួន ១៥.៤៥០ ដុល្លារ

៧-ឧបាសក **ឌុយ សុខ** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៤.៨០០ ដុល្លារ

៨-ឧបាសក **អ៊ុក សារ៉េត** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកាចំនួន ១៤.៧៦០ ដុល្លារ

p

៩-ឧបាសក អៀង លី	សប្បុរសជននៅខេត្តកំពង់ស្ពឺ	ថវិកាចំនួន ១៤.៧០០ ដុល្លារ
១០-ឧបាសក ឃួន ម៉ុន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ១៤.៦៥០ ដុល្លារ
១១-ឧបាសិកា ស្វាយ ណាង	សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១៣.៦៥០ ដុល្លារ
១២-ឧបាសិកា មាស ចន្ថា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន១៣.០០០ ដុល្លារ

ខ. មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៩ គ្រឿង ផ្តល់ជូន :

១-ឧបាសក ពុង យ៉ាង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៧.៧៦០ ដុល្លារ
២-ឧបាសក សរ រ៉ុម	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៧.៥៦០ ដុល្លារ
៣-ឧបាសក ស៊ើ សារត	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៧.៥៥០ ដុល្លារ
៤-ឧបាសក ជា ម៉េងស្រួ	សប្បុរសជននៅខេត្តកណ្តាល	ថវិកាចំនួន ៧.៥៥០ ដុល្លារ
៥-ឧបាសក ម៉ុត សៀង	សប្បុរសជននៅខេត្តកណ្តាល	ថវិកាចំនួន ៧.៥០០ ដុល្លារ
៦-ឧបាសិកា សំ ម៉ាក់ឆួក	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៦.៨៧០ ដុល្លារ
៧-ឧបាសិកា កែវ សុខុម	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៦.៨៥០ ដុល្លារ
៨-ឧបាសក សុខ យ៉ាន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកាចំនួន ៦.៧៥០ ដុល្លារ
៩-ឧបាសិកា អ៊ូ ឡៀន	សប្បុរសជននៅខេត្តកំពង់ស្ពឺ	ថវិកាចំនួន ៦.៥០០ ដុល្លារ

មាត្រា ២.–

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **ជឹម គឹមជាតិ** ព្រះគ្រូសូត្រស្តាំវត្តឥសីគីរីជុំ ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ **វត្តឥសីគីរីជុំ** (ហៅវត្តត្រពាំងឫស្សី) ស្ថិតនៅក្នុងឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ចំណាយអស់ថវិកាសរុបចំនួន ៤៧.៥០០ ដុល្លារ ។

មាត្រា ២.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៩.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់គ្រឿងឥស្សរិយយសមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **Teddy Hailamsah** សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជាដែលជាក្រុមហ៊ុនចំរុះរដ្ឋ ក្នុងការសហការរួមចំណែករកចំណូលថវិកាជាតិ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ១៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ចំនួន០២គ្រឿង ជូនអគ្គអធិការកិច្ចរដ្ឋាភិបាល និងសាលាបណ្តុះបណ្តាលកម្មាភិបាលអធិការកិច្ច នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ លើវិស័យអធិការកិច្ចជាមួយក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ចកម្ពុជា ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ:

-GOVERNMENT INSPECTORATE OF VIETNAM

ខ-មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ:

-INSPECTOR TRAINING SCHOOL OF GOVERNMENT INSPECTORATE OF VIETNAM

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤១ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចំនួន៣៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច លើវិស័យវប្បធម៌និងវិចិត្រសិល្បៈ ដូចមានរាយនាមខាងក្រោម ៖

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១- លោក អ៊ុម គីមលន អធិការ នៃអធិការដ្ឋាន

២- លោក វ៉ា វ៉ាន់ថេត អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់សេនា :

១. លោក គង់ ប៊ូលីន ប្រធាននាយកដ្ឋាន នៃនាយកដ្ឋានបុរាណវត្ថុ

២. លោកស្រី រស់ សារ៉ូ ប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសៀវភៅ និងការអាន

៣. លោក ឈឹម លាងសេង ប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

៤. លោកស្រី រស់ សុខុន អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសៀវភៅ និងការអាន

៥. លោកស្រី ខ្វត វិបុលឡា អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសៀវភៅ និងការអាន

៦. លោក ឡុង តាត ជំនួយការ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

៧. លោក ពុធ សំណាង អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

៨. លោក ដេត សុវត្ថា អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

៩. លោក ឈឹម សុធី អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម

១០. លោក អ៊ី រី ប្រធានមន្ទីរ នៃមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្តស្វាយរៀង

p

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន១៩រូប មានស្នាដៃល្អ ក្នុងកិច្ចសហការជាមួយនាយទាហាន កងពលតូចលេខ៧០ ជួយសម្របសម្រួលក្នុងការងារបោះបង្គោល កំណត់ទីតាំងព្រំដីនៅឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដើម្បីសាងសង់មូលដ្ឋានយុទ្ធសាស្ត្ររឹងមាំ សម្រាប់រក្សាទុកសម្ភារៈបច្ចេកទេសយោធា និងបានជួយឧបត្ថម្ភថវិកា សម្ភារៈ ជូនដល់កងពលតូចលេខ៧០ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-លោក	ចាន់	សួខ	នាយករងទីចាត់ការអន្តរវិស័យ សាលាខេត្តកំពង់ស្ពឺ
២-លោក	គង់	ធុំ	មេឃុំក្រាំងអំពិល ស្រុកសំរោងទង សាលាខេត្តកំពង់ស្ពឺ
៣-លោក	គីម	គមរ៉ា	មន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្តកំពង់ស្ពឺ
៤-លោក	អ៊ុំ	ចាមរិន	អនុប្រធានការិ.រៀបចំដែនដីនគរូបនីយកម្មនិងភូមិបាលស្រុកគងពិសី ខេត្តកំពង់ស្ពឺ
៥-លោក	ឆៀង	ជារ៉ា	មន្ត្រីការិ.រៀបចំដែនដីនគរូបនីយកម្ម និងភូមិបាល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
៦-លោក	សែន	សឿន	នាយរងសង្កាត់រដ្ឋបាលព្រៃឈើស្រង់ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ
៧-លោក	រស់	ថុី	សមាជិកក្រុមប្រឹក្សាឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
៨-លោក	សាត់	ឫទ្ធី	អនុប្រធានការិ.គ្រប់គ្រងការអភិវឌ្ឍន៍និងសំណង់ សាលាខេត្តកំពង់ស្ពឺ
៩-លោក	វិន្ន	យ៉ឹម	សមាជិកក្រុមប្រឹក្សាឃុំស្គុះ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

ខ-មេដាយប្រាក់ការងារ

១-លោក	គីម	លន	មេភូមិថ្នល់បត់ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

p

២-លោក គីម ទន មេភូមិថ្មកជួនសុខ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
៣-លោក សួស ធីន មេភូមិតានុង ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
៤-លោក ម៉ែន នឿន មេភូមិអង្វែ ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
៥-លោក យ៉ាន ខន មេភូមិរលួស ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ

មាត្រា ២..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អគ្គមេបញ្ជាការកងយោធពល ខេមរភូមិន្ទត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ឯកឧត្តម សៀង ណាំ អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ០៦រូប ដែលមានស្នាដៃល្អ ក្នុងការជួយកសាង ព្រះវិហារ វត្តបូណ៌ខ្នាតេជោ និងសមិទ្ធផលនានា ស្ថិតនៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

១-លោក	អែម ស៊ើន	ប្រធានក្រុមប្រឹក្សាស្រុកក្រឡាញ់ ខេត្តសៀមរាប
២-លោក	ឡុង រដ្ឋរក្ស	អភិបាលរងស្រុកក្រឡាញ់ ខេត្តសៀមរាប
៣-លោកវរសេនីយ៍ទោ អ៊ុំ ឃួច		នាយរងការិយាល័យទី២ យោធភូមិភាគ ៤

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-លោក	អ៊ុច សេរីឌី	ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប
២-លោក	ចិន គីមស្រេង	អនុប្រធានសាខាពន្ធដារ ខេត្តសៀមរាប
៣-លោក	តាន់ ម៉ិនចេង	អនុប្រធានសភាពាណិជ្ជកម្ម ខេត្តសៀមរាប

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៥៥...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ហាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ឯកឧត្តម សៀង ណាំ អ្នកតំណាងរាស្ត្រមណ្ឌលសៀមរាប

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ហាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនមន្ត្រីរាជការ សប្បុរសជន ២៨រូប ដែលមានស្នាដៃល្អ ក្នុងការជួយកសាង ព្រះវិហារ វត្តបូណ៌ខ្នាតេជោ និងសមិទ្ធផលនានា ស្ថិតនៅក្នុងស្រុកក្រឡាញ់ ខេត្តសៀមរាប សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសស្ហាបនាជាតិ

១-	វរសេនីយ៍ត្រី	ចាន់ សារ៉េន	អធិការនគរបាលស្រុកក្រឡាញ់ ខេត្តសៀមរាប
២-	វរសេនីយ៍ត្រី	គង់ ម៉ាត់	មេបញ្ជាការផ្នែកសឹករងក្រឡាញ់ ខេត្តសៀមរាប
៣-	អនុសេនីយ៍ឯក	ម៉ុន ម៉ាខឺន	មេបញ្ជាការកងរាជអាវុធហត្ថស្រុកក្រឡាញ់ ខេត្តសៀមរាប
៤-	លោក	ដោ ធិរុទ្ធ	នាយសង្កាត់រដ្ឋបាលព្រៃឈើក្រឡាញ់-ស្រីស្នំ
៥-	លោក	ម៉ក់ ម៉ុនចាន់	នាយករងរដ្ឋបាល សាលាស្រុកក្រឡាញ់ ខេត្តសៀមរាប
៦-	លោក	ស៊ិន ព៌	ប្រធានការិយាល័យអន្តរវិស័យ សាលាស្រុកក្រឡាញ់ ខេត្តសៀមរាប
៧-	លោកស្រី	ជី ឡាទី	សមាជិកគណៈកម្មាធិការអនុសាខាកាកបាទក្រហមកម្ពុជា ស្រុកក្រឡាញ់
៨-	លោក	ដែន ដែរ៉េត	សមាជិកគណៈកម្មាធិការអនុសាខាកាកបាទក្រហមកម្ពុជា ស្រុកក្រឡាញ់
៩-	លោក	យី យឿ	សប្បុរសជននៅសហរដ្ឋអាមេរិក

ខ-មេដាយប្រាក់ស្ហាបនាជាតិ

១-	ព្រះតេជគុណ	សុច សយ	ព្រះគ្រូចៅអធិការវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
២-	លោក	ម៉ុន ឈឿន	មេឃុំចន្លាស់ដៃ ស្រុកក្រឡាញ់ ខេត្តសៀមរាប
៣-	លោក	សុខ តារុណ	ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ សាលាស្រុកក្រឡាញ់
៤-	លោក	សុខ ណារ៉េត	ប្រធានការិយាល័យផែនការ និងគាំទ្រឃុំ សាលាស្រុកក្រឡាញ់

p

៥-	ឧបាសិកា	ឈួន រិទ	សប្បុរសជនភូមិពេជ្ជោរ ឃុំក្រឡាញ់ ស្រុកក្រឡាញ់
៦-	ឧបាសិកា	អ៊ុល យន់	សប្បុរសជនភូមិពេជ្ជោរ ឃុំក្រឡាញ់ ស្រុកក្រឡាញ់
៧-	ឧបាសក	ចាប់ ម៉ាត់	សប្បុរសជនភូមិចំបក់ហែរ ឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់

គ-មេដាយសេរីវឌ្ឍនៈស្ថាបនាជាតិ

១-	លោក	ហាយ សារ៉េត	មន្ត្រីការិយាល័យធម្មការ និងសាសនាស្រុកក្រឡាញ់
២-	លោក	អ៊ិន ទន់	ជំទប់ទី១ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៣-	លោក	ភ្លឹម ឈឹម	សមាជិកក្រុមប្រឹក្សា ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៤-	លោកស្រី	នួច ថា	សមាជិកក្រុមប្រឹក្សា ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៥-	លោក	ធំ ម៉ុត	មេភូមិខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៦-	លោក	នូ ម៉ឿន	គណៈកម្មការវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៧-	លោក	ញួន គឿន	គណៈកម្មការវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៨-	លោក	ឈុត ឈឿង	គណៈកម្មការវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
៩-	លោក	នាយ ស៊ីន	គណៈកម្មការវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
១០-	លោក	គិន ឃត់	អាចារ្យវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
១១-	លោក	ឈឹន សាយ	អាចារ្យវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់
១២-	លោក	ម៉ុត ទិល	អាចារ្យវត្តបូណ៌ខ្នាតេជោ ឃុំចន្លាស់ដៃ ស្រុកក្រឡាញ់

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

155

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសមាជិកក្រុមការងារ ចំនួន ០៤រូប ដែលមានស្នាដៃល្អ ក្នុងការងារជួយកសាង អគារសិក្សា និងសមិទ្ធផលនានា នៅក្នុងសាលាបឋមសិក្សាអ្នកឧកញ៉ាមហាភក្តី ហ៊ុន នាង បាក់ខែង ស្ថិតក្នុងសង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម៖

១- លោក ពៅ ម៉េងហេង

២- លោក អួន រស្មី

៣- លោក ខាន់ ម៉ិនធី

៤- លោក រ៉ែន សេរី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៥រូប ដែលបានបរិច្ចាគធនធាន ផ្ទាល់ខ្លួនជួយកសាង អគារសិក្សា និងសមិទ្ធផលនានា នៅក្នុងសាលាបឋមសិក្សាអ្នកឧកញ៉ាមហាភក្តី ហ៊ុន នាង បាក់ខែង ស្ថិតក្នុងសង្កាត់បាក់ខែង ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម៖

១- លោក **សោម រស្មី**

២- លោក **ម៉ិន ស៊ីនាថ**

៣- លោក **ហ៊ិន សុផាត**

៤- លោក **ពេជ្រ យ៉ុន**

៥- លោក **គីម ឈុនលី**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ២៩រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង អភិវឌ្ឍន៍ ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ អោយមានការរីកចម្រើនកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ

០១-ឧកញ៉ាបណ្ឌិត **សាន ស៊ានហូ** ចៅសង្កាត់ប៉ោយប៉ែត ថវិកា៨៦.៥៥០ ដុល្លាអាមេរិក

០២-លោក **ទ៉ាន់ ឆុង** ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់

០៣-លោក **សាន ពុទ្ធារី** ប្រធាននាយកដ្ឋានសោតទស្សន៍ នៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន

០៤-លោកវរសេនីយ៍ត្រី **ស៊ុំ សុឃីម** អត្តលេខ ០៩២៤៤ អធិការរងស្រុកព្រែកប្រសព្វ ស្នងការដ្ឋាននគរបាលខេត្តក្រចេះ

០៥-លោកវរសេនីយ៍ត្រី **ស្រី ខាសនា** អត្តលេខ ១៣៤៤២៥ នាយការិយាល័យបុគ្គលិក អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

០៦-លោក **សៅ ចាន់ណា** អនុប្រធានការិយាល័យ នៃមន្ទីរធនធានទឹក ខេត្តព្រៃវែង

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា

១-ឯកឧត្តម **ឱុន តត្ថិ** សាកលវិទ្យាធិការ សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ថវិកា៣៦.៥៥០ ដុល្លាអាមេរិក

២-លោក **គង់ សុខ** សមាជិកក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត

៣-លោក **ហេង ម៉េងលី** សមាជិកក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត

៤-លោក **ស្រិល អ៊ុន** សមាជិកក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត

៥-លោក **ម៉ែន ទិន** សមាជិកក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត ថវិកា៣៦.៥៥០ ដុល្លាអាមេរិក

៦-លោក **ទ៉ា ឋិមណារ៉េត** សមាជិកក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត

៧-លោក **ឈាង សុខ** សមាជិកក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត

៨-លោក **យឿត ធិន** សប្បុរសជនសង្កាត់ប៉ោយប៉ែត ថវិកា៣១.២០០ ដុល្លាអាមេរិក

៩-លោក **ហៃ ឧុទ្ធី** សប្បុរសជនសង្កាត់ប៉ោយប៉ែត ថវិកា២៨.៩០០ ដុល្លាអាមេរិក

p

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

១-ឯកឧត្តម **ម៉ីង ដាវ័ន** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ថវិកា២១.៥០០ ដុល្លាអាមេរិក

២-ឯកឧត្តម **ឆៃ ម៉េងហុក** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ថវិកា២១.០០០ ដុល្លាអាមេរិក

៣-ឯកឧត្តម **សាន គេង** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ថវិកា២០.៥០០ ដុល្លាអាមេរិក

៤-លោក **ពុំ សុតិន**	ស្មៀនសង្កាត់ប៉ោយប៉ែត
៥-លោក **យ៉ុត ម៉ៃយ៉ាន**	គណៈកម្មការអភិវឌ្ឍន៍សង្កាត់ប៉ោយប៉ែត
៦-លោក **ស៊ុយ ណាង**	គណៈកម្មការអភិវឌ្ឍន៍សង្កាត់ប៉ោយប៉ែត
៧-លោក **ឡេង សុផល**	គណៈកម្មការអភិវឌ្ឍន៍សង្កាត់ប៉ោយប៉ែត
៨-លោក **រស់ ចន្ថា**	ជំនួយការក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត
៩-លោក **ហៀង សម្បត្តិ**	ជំនួយការក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត
១០-លោក **ទ្វី ចាន់ធូ**	នាយកសាខា សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តព្រះសីហនុ
១១-លោក **ស៊ិន ស៊ុមលី**	នាយករងសាខា សាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តព្រះសីហនុ
១២-លោកវរសេនីយ៍ទោ **អាន សំអុល**	អត្តលេខ ៦៣៣៨៩ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
១៣-លោកអនុសេនីយ៍ត្រី **ហេង ថេង**	អត្តលេខ ៣៨១៣៤ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
១៤-លោកអនុសេនីយ៍ត្រី **ណាំ សុចន្ថារ៉ា**	អត្តលេខ ៣៤៣០៨ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

158

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ៧៥រូប ដែលមានស្នាដៃល្អ ដោយបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង អភិវឌ្ឍន៍ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ អោយមានការរីកចម្រើនកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយមាសការងារ

០១-លោក **ងុំ សៀក** សមាជិកក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកពញាក្រែក
០២-លោក **គឹម ម៉េង** សមាជិកក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកពញាក្រែក
០៣-លោក **នុត សោភ័ណា** អនុប្រធាននាយកដ្ឋានពលកម្មកុមារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
០៤-វរសេនីយ៍ទោ **ពិន សុដែន** អត្តលេខ០៩៨២៤ មន្ត្រីការិយាល័យព្រហ្មទណ្ឌកម្រិតធ្ងន់ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០៥-លោក **អ៊ីង យ៉ាន** ប្រធានក្រុមប្រឹក្សាឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
០៦-លោក **យុល យ៉ុល** ជំទប់ទី១ ឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
០៧-លោក **សេង ចំរើន** សមាជិកក្រុមប្រឹក្សាឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
០៨-លោក **យឹម រស់** សមាជិកក្រុមប្រឹក្សាឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
០៩-លោកស្រី **ញ៉ែម យឿន** សមាជិកក្រុមប្រឹក្សាឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
១០-លោក **ប៉ោក ពុំ** សមាជិកក្រុមប្រឹក្សាឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
១១-លោក **លឹម សារ៉េត** សមាជិកក្រុមប្រឹក្សាឃុំមេបុណ្យ ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង
១២-លោក **អ៊ីង ហុកឆាយ** សមាជិកក្រុមការងារថ្នាក់កណ្តាលចុះជួយខណ្ឌឫស្សីកែវ
១៣-លោក **ភាត់ រាចនា** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
១៤-លោក **អៀន សារឿន** មេភូមិក្បាលស្ពាន១សង្កាត់ប៉ោយប៉ែត
១៥-លោក **អ៊ុំ សុផៃ** មេភូមិក្បាលស្ពាន២សង្កាត់ប៉ោយប៉ែត
១៦-លោក **សែម ធីរៈ** មេភូមិក្បាលកោះសង្កាត់ប៉ោយប៉ែត
១៧-លោកស្រី **ស៊ិន ណាំយ៉ុង** មេភូមិប៉ោយប៉ែត សង្កាត់ប៉ោយប៉ែត

p

១៨-លោក **ម៉ុំ ម៉ារិន** មេភូមិសាមគ្គីមានជ័យសង្កាត់ប៉ោយប៉ែត
១៩-លោកស្រី **ហុក លឿម** មេភូមិព្រៃព្រិច សង្កាត់ប៉ោយប៉ែត
២០-លោក **ឃុយ ហៀង** មេភូមិបាលិលេយ្យ១សង្កាត់ប៉ោយប៉ែត
២១-លោកស្រី **ថេង សុផារី** មេភូមិបាលិលេយ្យ២សង្កាត់ប៉ោយប៉ែត
២២-លោក **ហ៊ីង សាខន** មេភូមិអូរជ្រៅសង្កាត់ប៉ោយប៉ែត
២៣-លោក **សន មុន្នី** មេភូមិមិត្តភាពសង្កាត់ប៉ោយប៉ែត
២៤-លោក **សេង ចាន់ឌី** មេភូមិចាន់គីរីសង្កាត់ប៉ោយប៉ែត
២៥-លោក **សេង ឡុង** មេភូមិគីឡូលេខ៤សង្កាត់ប៉ោយប៉ែត
២៦-លោក **ខ្លែង សុឃ្លី** មេភូមិផ្សារកណ្តាលសង្កាត់ប៉ោយប៉ែត
២៧-លោក **ម៉ន សារ៉េត** មេភូមិស្ទឹងបត់សង្កាត់ប៉ោយប៉ែត
២៨-លោក **ខាន់ សំអឿន** មេភូមិអណ្តូងថ្មមាសសង្កាត់ប៉ោយប៉ែត
២៩-លោក **វ៉ាន់ ចំរើន** មេភូមិទួលពង្រសង្កាត់ប៉ោយប៉ែត
៣០-លោក **ឆាប គីមសាង** មេភូមិអូរឬស្សីសង្កាត់ប៉ោយប៉ែត
៣១-លោក **យឹម សាម៉ាន់** មេភូមិអូរនាងសង្កាត់ប៉ោយប៉ែត
៣២-លោក **ណាង សុង** មេភូមិព្រៃគុបសង្កាត់ប៉ោយប៉ែត
៣៣-លោក **សុខ កុយ** មេភូមិទួលប្រាសាទសង្កាត់ប៉ោយប៉ែត
៣៤-លោក **ស៊ី ចាន** មេភូមិទំនប់ក៥ សង្កាត់ប៉ោយប៉ែត
៣៥-លោក **កែវ សម្បត្តិ** មេភូមិប្រជាធម្មខាងលិចសង្កាត់ប៉ោយប៉ែត
៣៦-លោក **សុខ ទិមាន** មេភូមិប្រជាធម្មខាងកើតសង្កាត់ប៉ោយប៉ែត
៣៧-ភិក្ខុបិតយសោ **លោ ម៉ិនឡេង** ព្រះចៅអធិការវត្តគ
៣៨-ភិក្ខុបិតកម្មោ **ម៉ន មិន** ព្រះគ្រូសូត្រស្តាំវត្តគ
៣៩-អនុសេនីយ៍ត្រី **ខេន ម៉ូរ៉ុម** អត្តលេខ២៦៦២៦ មន្ត្រីនគរបាលប៉ុស្តិ៍ទួលស្វាយព្រៃ២រាជធានីភ្នំពេញ
៤០-លោក **គាព សុវណ្ណា** ជំនួយការប្រធានកងឯកភាពកំចាត់មីនទី២ ខេត្តបាត់ដំបង
៤១-លោក **កែវ លី** ប្រធានក្រុមជាងស៊ីម៉ាក់
៤២-លោកស្រី **ពៅ ចរិយា** អនុប្រធានការិយាល័យផែនការ នៃទីចាត់ការវិនិយោគសាលាខេត្តកំពង់ចាម
៤៣-លោក **ជ័យ គុម្ពិពល** អនុប្រធាននាយកដ្ឋានដំណឹងក្នុង និងក្រៅប្រទេស
៤៤-លោក **ជុំ សុគីន** មន្ត្រីសាលាខណ្ឌដូនពេញ
៤៥-លោក **នុត ប៊ុរី** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
៤៦-លោក **សៅ យ៉េង** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
៤៧-លោក **សឿ ប៉ំនិត** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
៤៨-លោក **ង៉ែ ចន្ទូ** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
៤៩-លោក **ផេង សារ៉ែន** មន្ត្រីនាយកដ្ឋានឧត្តមសិក្សា
៥០-អ្នកគ្រូ **ជា សុគន្ធ** សាស្ត្រាចារ្យវិទ្យាល័យសន្ធរម៉ុក
៥១-លោក **សៅ ហេង** មន្ត្រីសន្តិសុខ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា
៥២-លោក **គង់ សារ៉េត** មន្ត្រីសន្តិសុខ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា
៥៣-លោក **នង ពិធូ** មន្ត្រីសន្តិសុខ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា
៥៤-លោក **ឌួច សាមុធ** មន្ត្រីសន្តិសុខ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា
៥៥-លោក **គង់ ប៊ុនធឿន** មន្ត្រីសន្តិសុខ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា
៥៦-លោកស្រី **ផល សុភពចញ្ញា** មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា
៥៧-លោក **ហ៊ាង សុតា** សប្បុរសជននៅរាជធានីភ្នំពេញ
៥៨-លោកវរសេនីយ៍ទោ **ខឹម ម៉ុធ** អត្តលេខ ២២៨៥៦ មន្ត្រីនគរបាលទេសចរណ៍ នៃស្នងការនគរបាលខេត្តកំពង់ស្ពឺ
៥៩-លោកវរសេនីយ៍ត្រី **ម៉ុំ ម៉ូរ៉ា** អត្តលេខ ០៧៣១៨ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ

៦០-លោកពលបាលទោ **កែវ សារ៉ាត់** អត្តលេខ **៦២៩៨០** មន្ត្រីនគរបាលស្រុកឈូក
៦១-លោក **អៀក ជី** អនុប្រធាននាយកដ្ឋានរដ្ឋបាលក្រសួងព្រះបរមរាជវាំង
៦២-លោក **ឈិន ឧារាស្មី** មន្ត្រីក្រសួងព្រះបរមរាជវាំង
៦៣-លោកព្រិន្ទបាលទោ **នួន គឹម** អត្តលេខ ៥៥៤៦១ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ ខេត្តកំពត

ខ-មេដាយប្រាក់ការងារ

០១-អនុសេនីយ៍ទោ **ហេង ម៉ារ៉ាង** អត្តលេខ៥៣៩៣៨ មន្ត្រីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០២-អនុសេនីយ៍ទោ **ហ៊ុក គឹមហាន** អត្តលេខ៣៩០៨១ មន្ត្រីក្រសួងមហាផ្ទៃ
០៣-អនុសេនីយ៍ត្រី **ហេង សុវណ្ណគិរី** អត្តលេខ៥៧៣០៤ មន្ត្រីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០៤-ព្រិន្ទបាលឯក **លាង ច័ន្ទតេជា** អត្តលេខ៦២៩៤២ មន្ត្រីស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
០៥-លោក **សាំង ណាន** មន្ត្រីគយ និងរដ្ឋាករច្រកទ្វារព្រំដែនបាវិត
០៦-លោក **ហ៊ុក និត្យវង្សា** សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម
០៧-លោក **អន សុខាល័យ** សប្បុរសជននៅរាជធានីភ្នំពេញ
០៨-លោក **អ៊ឹម នឿន** មន្ត្រីសន្តិសុខ នៅអគ្គលេខាធិការដ្ឋានរដ្ឋសភា
០៩-លោក **គុយ សារ៉េន** សប្បុរសជននៅរាជធានីភ្នំពេញ

គ-មេដាយសំរិទ្ធការងារ

០១-លោកវរសេនីយ៍ត្រី **ចិន ធូ** អត្តលេខ៣៣៤០០ មន្ត្រីនាយកដ្ឋានអង្គរក្ស នៃក្រសួងមហាផ្ទៃ
០២-ព្រិន្ទបាលឯក **ចិន សុជាតាតារក្ស** អត្តលេខ៥៧២១៧ មន្ត្រីនគរបាលក្រសួងមហាផ្ទៃ
០៣-លោក **អន រដ្ឋា** សប្បុរសជននៅរាជធានីភ្នំពេញ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងសប្បុរសជន ០៨រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ចូលរួមកសាង អភិវឌ្ឍន៍ ប្រទេសជាតិ ទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ អោយមានការរីកចម្រើនកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយសុវត្ថារា ថ្នាក់ និមខិន្ទ

១-លោក ឌា តារុន	សប្បុរសជននៅរាជធានីភ្នំពេញ
២-លោក សោម ស៊ីថុន	សប្បុរសជននៅរាជធានីភ្នំពេញ
៣-លោក ជុន ជាតិ	សប្បុរសជននៅរាជធានីភ្នំពេញ
៤-លោក ជឹម សំអយ	សប្បុរសជននៅរាជធានីភ្នំពេញ
៥-លោក ឈាម សំអាត	សប្បុរសជននៅរាជធានីភ្នំពេញ

ខ-មេដាយសុវត្ថារា ថ្នាក់ សេនា

១-លោក ហ៊ុយ សម្បត្តិ	សប្បុរសជននៅរាជធានីភ្នំពេញ
២-លោក ជា ស្រេង	សប្បុរសជននៅរាជធានីភ្នំពេញ
៣-លោក តើត ឡឿន	អនុប្រធាននាយកដ្ឋានក្រសួងព្រះបរមរាជវាំង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១. សរណន

សារាចរណែនាំ
ស្តីពី
ការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា

ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបញ្ចូលជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក កាលពីថ្ងៃទី២៥និងទី២៦ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងទូបាគូគា ប្រទេសសេណេហ្គាល់ ដោយក្លឹបឆ្នេរស្អាតបំផុតលើពិភពលោក ដោយសារភាពសម្បូរបែបនៃជីវៈចម្រុះ ភាពប្រណីតនៃបរិស្ថានធម្មជាតិ តម្លៃអេកូឡូស៊ីសេដ្ឋកិច្ចសង្គម វប្បធម៌ និងប្រពៃណីក្នុងតំបន់ ព្រមទាំងភាពទាក់ទាញផ្នែកទេសចរណ៍។ ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ និងកំណើនប្រជាជននៅក្នុងតំបន់ឆ្នេរសមុទ្រ ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ទាមទារឲ្យមានការអភិវឌ្ឍផ្នែករូបវន្តសមស្រប ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា មានផែនការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាពនិងចីរភាព ដើម្បីចៀសវាងនិងទប់ស្កាត់ផលប៉ះពាល់ដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ចសង្គម បរិស្ថានវប្បធម៌ និងប្រពៃណីក្នុងតំបន់ឆ្នេរសមុទ្រ។

រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវសារាចរនេះ ដើម្បីណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យអនុវត្តនូវគោលការណ៍គ្រប់គ្រង ប្រើប្រាស់ ថែរក្សា ការពារ និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមានដែនគោក កោះ និងដែនទឹកដូចខាងក្រោម៖

១. ឆ្នេរសមុទ្រ

ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកានកាប់ឬសាងសង់នានាជាថ្មី ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០(សាមសិប)ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក។
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ)ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

p

នៅលើឆ្នេរសមុទ្រ អាចអនុញ្ញាតឲ្យដាក់ឆត្រ កៅអី និងតុតូចៗតាមចំនួនសមស្រប ដែលអាចផ្លាស់ប្តូរទីតាំងបាន សម្រាប់គោលដៅសម្រាកលំហែកាយនិងត្រូវរៀបចំដាក់តួបឆ្មាំឆ្នេរសមុទ្រ ដោយបំពាក់សម្ភារៈនិងឧបករណ៍ចាំបាច់តាមតម្រូវការ ដើម្បីឃ្លាំមើលនិងការពារសុវត្ថិភាពជូនសាធារណជននិងអ្នកទេសចរ។

២- ដីចំណីឆ្នេរសមុទ្រនិងការប្រើប្រាស់

ដីចំណីឆ្នេរសមុទ្រ ជាទូទៅប្រើប្រាស់សម្រាប់ជាសួនបៃតងនិងបណ្តាញទេសភាពឬសម្រាប់ដាំដើមឈើសម្គាល់ព្រំឆ្នេរនិងចំណីឆ្នេរដោយបន្តទៅជាប់នឹងផ្លូវសាធារណៈដែលស្ថិតក្នុងទិសខាងដីគោក។

២.១- ដីចំណីឆ្នេរសមុទ្រ

ដីចំណីឆ្នេរសមុទ្រ គឺជាផ្ទៃដីដែលចាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។

ប្រវែងឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់យ៉ាងតិច៥០(ហាសិប)ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក

- ក្នុងករណីដែលកាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

២.២- ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រ

ការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រមានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាមស្ថានភាពទីតាំងនីមួយៗ៖

ទី១- ដីចំណីឆ្នេរសមុទ្រដែលមានមនុស្សរស់នៅច្រើននិងមានលក្ខណៈជាទីប្រជុំជនឬមានសកម្មភាពទេសចរណ៍ ការប្រើប្រាស់ ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យសាងសង់ជាសំណង់តូបតូចៗសម្រាប់បម្រើដល់សេវាកម្មទេសចរណ៍នៅចន្លោះដើមឈើដែលមានចម្ងាយពីតូបមួយទៅតូបមួយទៀតយ៉ាងតិច១៥(ដប់ប្រាំ)ម៉ែត្រ ដើម្បីសម្រួលដល់ការឆ្លងកាត់របស់សាធារណជននិងអ្នកទេសចរ និងរក្សាគំហើញទៅលំហសមុទ្រ។ សំណង់តូបតូចៗនេះត្រូវរៀបចំឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសនិងមានច្រកដើរចេញចូលច្បាស់លាស់ដើម្បីចៀសវាងផលប៉ះពាល់ដល់សួនច្បារនិងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យមានសំណង់ជានិមិត្តរូបផ្សេងៗ ជាលក្ខណៈរូបចម្លាក់ស្តូប ឬសិល្បៈសាធារណៈ
- អាចអនុញ្ញាតឲ្យមានចំណតយានយន្តទេសចរគ្រប់ប្រភេទចូលចតក្នុងបរិវេណដីចំណីឆ្នេរសមុទ្រ ដែលមិនប៉ះពាល់ដល់សួនច្បារ និងទេសភាពបៃតង
- អាចអនុញ្ញាតឲ្យសាងសង់ជាបង្គន់អនាម័យសាធារណៈដែលមានលក្ខណៈសោភណភាព និងចំនួនសមស្រប សម្រាប់បម្រើដល់សាធារណជននិងអ្នកទេសចរ ដោយស្ថិតនៅតាមទីតាំងសមស្របនិងមិនប៉ះពាល់ដល់ទស្សនីយភាពតំបន់
- មិនអាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែពាណិជ្ជកម្ម លើកលែងតែកំពង់ផែដែលមានស្រាប់ និងទីតាំងដែលមានសក្តានុពលខ្លាំងនិងចាំបាច់សម្រាប់សាងសង់កំពង់ផែ។

- មិនអាចអនុញ្ញាតឲ្យមានសំណង់រឹងមាំនៅលើដីចំណីឆ្នេរសមុទ្រ លើកលែងតែសំណង់នោះត្រូវសាងសង់ឡើងក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈនិងទេសចរណ៍ដូចជា៖
  - ច្រកចូលឬស្ពានសម្រាប់តភ្ជាប់ទៅកាន់កំពង់ផែ ដែលមានទូកទេសចរណ៍ឬទូកម៉ាស៊ីនតូចៗសម្រាប់ភ្ញៀវទេសចរឬសាធារណជនប្រើប្រាស់។ កំពង់ផែទាំងនេះត្រូវមានទីតាំងសមស្រប និងមិនរំខានដល់សកម្មភាពឆ្លងកាត់ឆ្នេរសមុទ្រ
  - សារមន្ទីរជីវៈចម្រុះ រុក្ខជាតិសមុទ្រ ត្រីសមុទ្រ(Aquariums) ដែលនៅផ្នែកខាងមុខសំណង់ស្ថាបត្យកម្មនេះអាចឲ្យភ្ញៀវទេសចរឬសាធារណជនអាចឆ្លងកាត់បាន
  - ទីតាំងផ្សេងទៀតដែលរាជរដ្ឋាភិបាលអនុញ្ញាត។

ទី២- ដីចំណីឆ្នេរសមុទ្រស្ថិតក្នុងតំបន់ដែលមិនមានមនុស្សរស់នៅច្រើននិងមិនមែនជាទីប្រជុំជន ការប្រើប្រាស់ត្រូវបានកំណត់ដូចខាងក្រោម៖

- អាចអនុញ្ញាតឲ្យមានសំណង់កំពង់ផែ ពាណិជ្ជកម្ម ឬកំពង់ផែនេសាទ។ ចំពោះកំពង់ផែដែលមានស្រាប់ ត្រូវរៀបចំឲ្យមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹង។ ក្នុងករណីចាំបាច់ ត្រូវធ្វើការសិក្សាពីផលប៉ះពាល់បរិស្ថាននិងភាពសមស្របនៃទីតាំង ដើម្បីធានាសុវត្ថិភាពសុខុមាលភាពនិងការកាត់បន្ថយហានិភ័យផ្សេងៗ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាតំបន់ទេសចរណ៍លើទឹក កំពង់ផែទេសចរណ៍ ឬតំបន់កម្សាន្តថ្មីដោយមានការគ្រប់គ្រងអនាម័យនិងបរិស្ថាន ជាពិសេស កាកសំណល់រាវនិងកាកសំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីការពារធនធានទឹក ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ
- អាចអនុញ្ញាតឲ្យមានការរៀបចំជាភូមិទេសចរណ៍នៅក្នុងទីតាំងភូមិឋានថ្មីឬដែលមានស្រាប់ទៅតាមស្ថានភាពនិងសក្តានុពលជាក់ស្តែងនៃទីតាំងនីមួយៗ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃហេតុប៉ះពាល់បរិស្ថានឲ្យបានត្រឹមត្រូវ ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជា សំណង់រោងចក្រ ឧស្សាហកម្មរោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងពុលខ្ពស់ទៅក្នុងបរិយាកាសនិងបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង
- អាចអនុញ្ញាតឲ្យមានការអភិវឌ្ឍឬឲ្យមានសំណង់ផ្សេងទៀតស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។

៣- ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ គឺជាផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រ ដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះនិងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម[illegible]

p

ថែរក្សា ការពារ និងលើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ (ដប់ប្រាំ)ម៉ែត្រពីសងខាងអ័ក្សផ្លូវ។

៤- តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ

តំបន់រណប គឺជាតំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រនិងផ្លូវស្របបន្ទាប់មួយទៀត ដែលស្ថិតក្នុងទិសខាងដីគោក។

ការអភិវឌ្ឍនិងការសាងសង់សំណង់នានាក្នុងតំបន់នេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់សេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត។

ដើម្បីលើកកម្ពស់សោភណភាពបរិស្ថានធម្មជាតិនិងសំណង់ ការអភិវឌ្ឍសំណង់អគារក្នុងតំបន់រណបនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាប សម្រាប់គ្រប់ប្រភេទសំណង់អគារ ដូចមានចែងក្នុងបទដ្ឋាននគរូបនីយកម្ម
- ត្រូវរៀបចំឲ្យមានសួនច្បារ ដាំស្មៅ ដាំដើមឈើ និងមានផ្លូវថ្មើរជើងនៅលើចិញ្ចើមផ្លូវ ស្របតាមបទដ្ឋានបច្ចេកទេស
- ត្រូវរៀបចំជាលំហសាធារណៈ សួនច្បារ សួនកម្សាន្ត ឬឧទ្យានសាធារណៈជាដើម ដើម្បីលើកកម្ពស់សោភណភាពតំបន់ឆ្នេរសមុទ្រ
- ត្រូវមានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសម្រាប់រាល់ការដាក់តាំងស្លាកសញ្ញាពាណិជ្ជកម្ម។

៥- ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ

ផ្លូវសាធារណៈ ផ្លូវថ្មើរជើង និងសួនច្បារ ឬបណ្តាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រដែលតភ្ជាប់ទៅចំណុចប្រសព្វនិងផ្លូវដែលជាប់នឹងដីចំណីឆ្នេរសមុទ្រត្រូវ៖

- រក្សាទុកចិញ្ចើមសងខាងយ៉ាងតិច៦(ប្រាំមួយ)ម៉ែត្រ ចំពោះកំណាត់ផ្លូវសាធារណៈនៅក្នុងតំបន់រណប ដើម្បីរៀបចំឲ្យមានសួនច្បារ ការដាំស្មៅ ការដាំដើមឈើព្រមទាំងផ្លូវថ្មើរជើងស្របតាមបទដ្ឋានបច្ចេកទេស
- រៀបចំឲ្យមានសួនច្បារ ការដាំស្មៅ និងការដាំដើមឈើអមសងខាងតាមស្ថានភាពជាក់ស្តែងនិងស្របតាមបទដ្ឋានបច្ចេកទេសចំពោះផ្លូវថ្មើរជើងដែលមានស្រាប់ឬបង្កើតថ្មី
- ត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើនបង្កើតជាបណ្តាញបៃតងភ្ជាប់ទៅនឹងដីចំណីឆ្នេរសមុទ្រ ចំពោះផ្ទៃដីឬលំហសាធារណៈដែលស្ថិតនៅជាប់ផ្លូវសាធារណៈដែលមានស្រាប់ឬបង្កើតថ្មី ដើម្បីលើកកម្ពស់សោភណភាពបរិស្ថាននិងជាការបើកច្រកខ្យល់ជំនោរសមុទ្រ។

51

p

ដែសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ

ដៃសមុទ្រគឺជាផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដៃសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ កជោរខ្ពស់បំផុត។ ទំហំដីចំណីដៃសមុទ្រ ត្រូវកំណត់ចម្ងាយ៣០(សាមសិប)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរ ស់បំផុត។

ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានគឺជាផ្ទៃទឹកសាបដែលតភ្ជាប់ទៅនឹងផ្ទៃទឹក មុទ្រ។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់ ម៉ិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ២០(ម្ភៃ)ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់ តនៅរដូវវស្សា។

ផ្លូវសាធារណៈតាមបណ្តោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែត ន គឺជាផ្លូវដែលសាងសងឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ក្បូនចេញចូលបាន បណ្តែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវា ក្បូនចេញចូលបាន បណ្តែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណី សមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបានឬបណ្តែតបាន។

ក្នុងករណីដែលពុំទាន់មានផ្លូវសាធារណៈខាងលើនេះ ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តួច មរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាព មស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម ក្នុងគោលដៅថែរក្សាការពារ លើកកម្ពស់សោភណភាពបរិស្ថានក្នុងតំបន់ឆ្នេរសមុទ្រ។ ផ្លូវនេះត្រូវមានដីចំណីផ្លូវយ៉ាងតិច១០(ដប់)ម៉ែត្រពីសង ងអ័ក្សផ្លូវ។

នៅតាមបណ្តោយផ្លូវសាធារណៈនេះត្រូវរៀបចំឲ្យមានសួនច្បារ វាលស្មៅ និងផ្ទៃដីដាំដើមឈើឲ្យបានច្រើន ត្តិតជាបណ្តាញបៃតង ដើម្បីលើកកម្ពស់សោភណភាពនិងបរិស្ថាន។

ការអភិវឌ្ឍជាសំណង់អគារផ្សេងៗនៅជាប់ផ្លូវសាធារណៈនេះ ត្រូវមានសន្ទស្សន៍ទាបដូចក្នុងតំបន់រណបតាម ណ្តោយផ្លូវជាប់នឹងដីចំណីឆ្នេរសមុទ្រដែរ។

- កោះ

កោះ ជាផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរ តិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមាន កំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍ សេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

១- ការប្រើប្រាស់និងការអភិវឌ្ឍកោះក្នុងកម្មវត្ថុសម្រាប់ការរស់នៅ

លើកលែងតែមានការហាមឃាត់ដោយច្បាប់ កោះមួយចំនួនអាចត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ជាមណ្ឌល សន្ននិងមិនទៀងតាមរយៈកិច្ចសន្យាច្បាស់លាស់។ ការអភិវឌ្ឍកោះក្នុងកម្មវត្ថុនេះ ត្រូវគោរពតាមប្លង់គោលប្រើប្រាស់

p

ប្រាស់ដី និងផែនការប្រើប្រាស់ដីព្រមទាំងបទប្បញ្ញត្តិជាធរមានឬតាមផែនការអភិវឌ្ឍដែលរាជរដ្ឋាភិបាលឬក្រសួងស្ថាប័នមានសមត្ថកិច្ចបានអនុញ្ញាត។

ចំពោះកោះដែលអនុញ្ញាតឲ្យប្រើប្រាស់ក្នុងកម្មវត្ថុនេះ តែពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់ការអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែងនិងគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវរក្សានិងការពារធនធានធម្មជាតិ ព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិប)ភាគរយ
- ត្រូវមានសន្ទស្សន៍ទាប ដោយមានផលធៀបក្រឡាផ្ទៃបាតសំណង់ទាបជាង៣៥%(សាមសិបប្រាំ)ភាគរយ ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបចំដាំដើមឈើនិងធ្វើជាសួនបៃតងយ៉ាងតិច៥០% (ហាសិប)ភាគរយ
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ
- ត្រូវរៀបចំឲ្យមានលំហសាធារណៈនិងតំបន់កម្សាន្តនានាឲ្យបានច្រើនជាអតិបរមាដើម្បីជំរុញការមកលេងកម្សាន្តរបស់សាធារណជននិងអ្នកទេសចរ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចអនុញ្ញាតឲ្យសាធារណជនទូទៅឬអ្នកទេសចរចេញចូលបាន
- ត្រូវរៀបចំឲ្យមានតំបន់កម្សាន្តនានាក្នុងករណីមានឆ្នេរខ្សាច់ និងរៀបចំកសាងផ្លូវសាធារណៈនៅក្បែរឆ្នេរនេះ ស្របតាមស្ថានភាពនៃទីតាំងរបស់កោះ។ ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធត្រូវផ្តួចផ្តើមរៀបចំគម្រោងកសាងផ្លូវនេះ និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យភាពសមស្របតាមគោលនយោបាយនិងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។ ផ្លូវសាធារណៈ ត្រូវមានទំហំសមស្របតាមបទដ្ឋានបច្ចេកទេសនិងតម្រូវការនៃការប្រើប្រាស់យូរអង្វែង
- ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការប៉ះពាល់ដល់បរិស្ថាន
- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រជាដើម ដែលមាននៅជុំវិញកោះសម្រាប់គោលដៅទេសចរណ៍។

៧.២- ការអភិវឌ្ឍនិងការសាងសង់នៅលើកោះក្នុងកម្មវត្ថុផ្សេងក្រៅពីការរស់នៅ

រាជរដ្ឋាភិបាលកម្ពុជាអាចធ្វើការអភិវឌ្ឍកោះដោយផ្ទាល់ ឬសហការជាមួយវិស័យឯកជនឬផ្តល់សិទ្ធិឲ្យឯកជនធ្វើការអភិវឌ្ឍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានការសម្រេចពីរាជរដ្ឋាភិបាល បុគ្គលដែលទទួលបានសិទ្ធិត្រូវរៀបចំផែនការអភិវឌ្ឍកោះ ជាលក្ខណៈរួមវន្តឲ្យបានសមស្រប និងដាក់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ពិនិត្យភាពសមស្របតាមគោលនយោបាយ និងបច្ចេកទេសរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ការអភិវឌ្ឍនេះ ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- ត្រូវមានសន្ទស្សន៍ទាបឬមធ្យម
  ត្រូវការពារធនធានធម្មជាតិនិងរក្សាព្រៃឈើដែលមានស្រាប់ឲ្យបានយ៉ាងតិច៦០%(ហុកសិបភាគរយ)
- ត្រូវសាងសង់សំណង់ដែលមានលក្ខណៈជាខ្មែរ

p

- ត្រូវរៀបចំប្លង់អភិវឌ្ឍន៍រូបវន្ត ដែលបង្ហាញពីការប្រើប្រាស់ដីតំបន់សាធារណៈ សួនច្បារ សួនឧទ្យាន បណ្តាញបៃតង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវសាធារណៈ ផ្លូវថ្មើរជើង ប្រព័ន្ធលូបង្ហូរ ប្រព័ន្ធចម្រោះទឹកកខ្វក់ ជាដើម ឲ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រ
- ត្រូវរៀបចំឲ្យមានកំពង់ផែនាវាចម្លងខ្នាតតូចឬកំពង់ផែទេសចរណ៍ ដែលអាចឲ្យអ្នកទេសចរនិងសាធារណជនទូទៅចេញចូលបាន តាមស្ថានភាពជាក់ស្តែងនិងមានទីតាំងសមស្រប

ត្រូវរៀបចំឲ្យមានការគ្រប់គ្រងកាកសំណល់រឹងនិងរាវ តាមបទដ្ឋានបច្ចេកទេស ដើម្បីចៀសវាងការបោះសំរាម និងការបង្ហូរទឹកកខ្វក់ចូលក្នុងសមុទ្រ មុនពេលធ្វើប្រតិបត្តិកម្ម

- ត្រូវធ្វើការថែរក្សា ការពារ កែច្នៃ និងប្រើប្រាស់ធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះគ្រប់ប្រភេទ ដូចជាផ្កាថ្ម ត្រី និងរុក្ខជាតិសមុទ្រ ដែលមាននៅជុំវិញកោះ ដើម្បីគោលដៅទេសចរណ៍

៧.៣- ចំពោះកោះដែលមិនមានភាពអំណោយផលដល់ការប្រើប្រាស់និងមិនអាចធ្វើការអភិវឌ្ឍផ្សេងៗបាន ត្រូវរក្សាទុកសភាពដើមសម្រាប់ជាប្រយោជន៍ដល់ការលើកកម្ពស់ទេសភាពសមុទ្រ។

៨. ដែនទឹកសមុទ្រ

ដែនទឹកសមុទ្រ សំដៅលើផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះគ្រប់ប្រភេទ។

ដែនទឹកសមុទ្រ ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះនានា ដូចជា ផ្កាថ្ម ត្រីធំតូចចម្រុះពណ៌ និងរុក្ខជាតិសមុទ្រត្រូវគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍឲ្យបានត្រឹមត្រូវ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព។

ការជិះនាវាឬទូកទេសចរណ៍គ្រប់ប្រភេទ ដូចជាទូកម៉ាស៊ីន អូប៊រ ម៉ូតូទឹក ជាដើម អាចធ្វើឡើងតែក្នុងបរិវេណអនុញ្ញាតប៉ុណ្ណោះដើម្បីសុវត្ថិភាពអ្នកទេសចរនិងជីវៈចម្រុះ។

ការអភិវឌ្ឍកំពង់ផែទេសចរណ៍ឬទីតាំងកម្សាន្តបណ្តែតទឹកនិងក្នុងទឹកនានា ត្រូវស្នើសុំការអនុញ្ញាតពីគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍឆ្នេរសមុទ្រកម្ពុជា ដើម្បីពិនិត្យភាពសមស្របនៃទីតាំង តាមគោលនយោបាយ និងបទដ្ឋានបច្ចេកទេសរៀបចំដែនដីនិងនគរូបនីយកម្ម។

ការនេសាទក្នុងតំបន់ដែលមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះត្រូវហាមឃាត់ លើកលែងតែការនេសាទជាលក្ខណៈទេសចរណ៍ដោយប្រើប្រាស់ឧបករណ៍នេសាទគ្រួសារ។

ការបូមខ្សាច់និងការសាងសង់សំណង់ផ្សេងៗនៅក្នុងដែនទឹកសមុទ្រ ដូចជាស្ថានីយសិក្សាស្រាវជ្រាវអំពីសមុទ្រ ស្ថានីយរុករកប៉ែជាដើម ត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាល។

រាល់ទីតាំងសំណង់លើទឹកទាំងអស់ ត្រូវរក្សាច្រកផ្លូវនាវាធំៗចេញចូលកំពង់ផែ។

៩. ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រ

៩.១- រាល់ការប្រគល់សិទ្ធិឲ្យឯកជនធ្វើការវិនិយោគនិងអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

- រៀបចំឲ្យមានច្រកចេញចូលនៅតាមបណ្តោយឆ្នេរសមុទ្រ ដើម្បីអាចឲ្យភ្ញៀវទេសចរនិងសាធារណជនចេញចូលដើរលេងកម្សាន្តនិងប្រើប្រាស់បាន

p

- អនុវត្តតាមប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី និងបទប្បញ្ញត្តិជាធរមាន។ ចំពោះទីតាំងដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំសេចក្តីណែនាំលម្អិតសម្រាប់អនុវត្ត
- ត្រូវរៀបចំឲ្យមានប្រព័ន្ធគ្រប់គ្រងកាកសំណល់រាវ ដោយរៀបចំឲ្យមានអាងចម្រោះ ប្រព័ន្ធលូ និងប្រព័ន្ធគ្រប់គ្រងគុណភាពទឹក និងគ្រប់គ្រងកាកសំណល់រឹង ស្របតាមបទដ្ឋានបច្ចេកទេស ចំពោះរាល់ការអភិវឌ្ឍ
- ត្រូវធ្វើការសិក្សាទីតាំងនិងវាយតម្លៃផលប៉ះពាល់បរិស្ថាន ឲ្យបានត្រឹមត្រូវម៉ត់ចត់ស្របតាមបទដ្ឋានបច្ចេកទេស នូវរាល់សំណើសុំធ្វើការអភិវឌ្ឍសំណង់នានា ដូចជាសំណង់រោងចក្រ ឧស្សាហកម្ម រោងជាង និងស្ថានីយផ្សេងៗជាដើម ដែលអាចមានកម្រិតបញ្ចេញផ្សែងបំពុលខ្ពស់ទៅក្នុងបរិយាកាស និងកម្រិតបញ្ចេញសំឡេងរំខានខ្លាំងដល់តំបន់ជិតខាង។

៩.២- រាល់ការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រនិងកោះនិងការធ្វើសកម្មភាពសេដ្ឋកិច្ចនិងទេសចរណ៍ ត្រូវធានាដល់សុវត្ថិភាពសាធារណៈ សង្គម និងបរិស្ថាន ដោយត្រូវគោរពតាមច្បាប់ បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

១០- សារាចរណែនាំនេះមិនមានផលប្រតិសកម្មទេ។

១១- សារាចរណែនាំនេះមិនពាក់ព័ន្ធទៅនឹងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីច្បាប់សមុទ្រ ឆ្នាំ១៩៨២ ទេ។

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ព្រមទាំងផែនការគ្រប់គ្រងការអភិវឌ្ឍក្នុងតំបន់ឆ្នេរសមុទ្រជាបន្ទាន់នូវរាល់ទីតាំងទាំងឡាយណាដែលពុំទាន់មានប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដី ដើម្បីសុំការសម្រេចពីស្ថាប័នមានសមត្ថកិច្ចនិងដាក់ឲ្យប្រើប្រាស់ជាផ្លូវការ។

ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធនៃបណ្តាខេត្តតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តខ្លឹមសារនៃសារាចរណែនាំនេះឲ្យមានប្រសិទ្ធភាពនិងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយរាយការណ៍ពីលទ្ធផលនៃការអនុវត្តមករាជរដ្ឋាភិបាលវិញ។

រាជធានីភ្នំពេញ [illegible] ខែកុម្ភៈ ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
  ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤៥១ ពណ.ចបព

ភ្នំពេញថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០១០

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **វ៉ុង & មាស រេសថឺរេន**
WONG & MEAS RESTAURANT Co., Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ២៣៧៧KH/២០១០ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទម្រង់ជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
២- អភិបាលក្រុមហ៊ុន : លោក DUPUIS ALAIN FRANÇOIS HENRI ALBERT "គតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក WONG KING MAN អភិបាល
លោក **សាន់ ថេត** "គតិយជន" អភិបាល
៣- ដើមទុនក្រុមហ៊ុន : ៤០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៩ ផ្លូវលេខ ១៦៣ សង្កាត់វាល់វង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ។
៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ ការផ្គត់ផ្គង់សំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

p

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានភារកិច្ចមកតំកលប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

កឹម_ស៊ីថន

<u>ចម្លងជូន</u>
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
  ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
  ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
  សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.សរ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ... ពណ.ចបព

ភ្នំពេញថ្ងៃទី ... ខែ ... ឆ្នាំ ២០...

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន	:	**ធី សុផានីម គ្រុប** **THY SOPHANIM GROUP Co., Ltd.**
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម	:	Co. ២៣៣0KH/២០១០ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១០
មានទ្រង់ទ្រាយជា	:	ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត
២ អភិបាលក្រុមហ៊ុន	:	លោកស្រី **ឌី ចាន់ធី** ប្រធានក្រុមប្រឹក្សាភិបាល លោកស្រី **ព្រហ្ម ផានីម** អភិបាល លោក **សៅ សុផា** អភិបាល លោក **សៅ ម៉ារីណា** អភិបាល លោកស្រី **ឌី ចាន់ស៊ីណែត** អភិបាល
៣- ដើមទុនក្រុមហ៊ុន	:	៦៨០.០០០.០០០ រៀល
៤- ទីស្នាក់ការក្រុមហ៊ុន	:	ភូមិ ៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម ។
៥- កម្មវត្ថុអាជីវកម្ម	:	-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង -អាជីវកម្មទទួលបញ្ចាំ និងទិញ លក់ ទ្រព្យបញ្ចាំ -អាជីវកម្មទទួលប្រតិភោគដោយអនុប្បទាន -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ -នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ -ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការផ្ទុកផុលសំភារៈ ទំនិញគ្រប់ប្រភេទ -ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ -មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ -បើកសាលារៀន -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម -សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម -សេវាផ្សាយពាណិជ្ជកម្ម -បោះពុម្ពផ្សាយ -ផលិតខ្សែភាពយន្ត វីដេអូ CD -ដឹកជញ្ជូន . ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ -សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

p

-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
